# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៥០០/០៩៧ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌអនុរក្សពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មកជាអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ .-**

ត្រូវបានបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ ចំណុះក្រសួងមហាផ្ទៃ។

**មាត្រា២ ..**

អគ្គនាយកដ្ឋានពន្ធនាគារ មានតួនាទីធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ ក្នុងការដឹកនាំ គ្រប់គ្រង ការងារឃុំឃាំង អប់រំកែប្រែពិរុទ្ធជន ទណ្ឌិត ឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ។

**មាត្រា៣ ..**

អគ្គនាយកដ្ឋានពន្ធនាគារដឹកនាំ គ្រប់គ្រង ដោយអគ្គនាយកមួយរូប និង មានអគ្គនាយករង មួយចំនួន ជាជំនួយការ ។

**មាត្រា៤ ..**

អគ្គនាយកដ្ឋានពន្ធនាគារ មានភារកិច្ចដូចខាងក្រោម :

- គ្រប់គ្រងមណ្ឌលអប់រំកែប្រែ និង ពន្ធនាគារ ខេត្ត ក្រុង ចំណុះក្រសួងមហាផ្ទៃ ត្រឹមត្រូវតាមច្បាប់កំណត់
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាន បទបញ្ជានានា ស្តីពីការងារគ្រប់គ្រងមណ្ឌលអប់រំកែប្រែ និង ពន្ធនាគារ ខេត្ត ក្រុង ដោយសហការជាមួយអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ
- ធ្វើចំណាត់ថ្នាក់សន្តិសុខ និង ឃុំឃាំងពិរុទ្ធជន ទណ្ឌិត ត្រឹមត្រូវតាមនីតិវិធីស្តីពីការគ្រប់គ្រងពន្ធនាគារ
- ដឹកនាំ គ្រប់គ្រង រាល់សកម្មភាពអនុវត្តន៍ច្បាប់ ក្នុងការឃុំឃាំងពិរុទ្ធជន ទណ្ឌិត ធានាបានសុវត្ថិភាព សន្តិសុខ និង សណ្តាប់ធ្នាប់។ បង្ការ ទប់ស្កាត់ និង ប្រឆាំងរាល់ឧបាយកលបង្ករចលាចល បំផ្លិចបំផ្លាញ ចាប់ជំរិត ឃាតកម្ម អត្តឃាត និង សកម្មភាពរំដោះពិរុទ្ធជន ទណ្ឌិត ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ និង អាជ្ញាធរមូលដ្ឋាន
- ផ្គត់ផ្គង់របបហូបចុក សម្ភារៈប្រើប្រាស់ ការស្នាក់នៅ ការថែរក្សាអនាម័យ ការព្យាបាលសុខភាព និង ការឧបត្ថម្ភផ្សេងទៀត ឱ្យបានត្រឹមត្រូវតាមច្បាប់ និង បទដ្ឋាននានារបស់រដ្ឋ
- លើកគំរោងផែនការ ថវិកា សម្ភារៈ ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូនប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានពន្ធនាគារ
- ចាត់វិធានការ ឃុំឃាំងពិរុទ្ធជន ឱ្យបានត្រឹមត្រូវ ដើម្បីសម្រួលដល់ការងារស៊ើបអង្កេតឱ្យមានដំណើរការល្អ
- រៀបចំគំរោងកម្មវិធីធ្វើនីតិសម្បទា តាមរយៈការអប់រំកែប្រែ បណ្តុះបណ្តាលវិជ្ជាជីវៈ កាយសិក្សា និង គ្រប់គ្រងពលកម្ម សិប្បកម្ម ដើម្បីលើកកម្ពស់ជីវភាព សុខភាពរបស់

ទណ្ឌិត និង កែប្រែអ្នកទាំងនោះ ឱ្យក្លាយជាពលរដ្ឋល្អ ពេលវិលត្រឡប់ទៅរស់នៅក្នុងសហគមន៍វិញ

- លើកសំណើបន្ធូរបន្ថយទោស លើកលែងទោស តាមការកំណត់របស់ច្បាប់ ។ អនុវត្តសាលដីកា សាលក្រមរបស់តុលាការ និងព្រះរាជក្រឹត្យប្រោសប្រទានបន្ធូរបន្ថយទោស លើកលែងទោសរបស់ព្រះមហាក្សត្រ
- បង្កើតប្រព័ន្ធទិន្នន័យ ស្តីពីការគ្រប់គ្រងពន្ធនាគារ
- គ្រប់គ្រងមន្ត្រីរាជការចំណុះអគ្គនាយកដ្ឋានពន្ធនាគារ ។ លើកសំណើ ជ្រើសរើស បណ្តុះបណ្តាល ហ្វឹកហ្វឺនជំនាញ តែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ ថ្នាក់ លើកសរសើរ អនុវត្តវិន័យ និង អនុវត្តគោលនយោបាយនានា តាមការកំណត់របស់ក្រសួងមហាផ្ទៃ
- លើកគំរោង សាងសង់ ជួសជុល និង អភិវឌ្ឍន៍មណ្ឌលអប់រំកែប្រែ ពន្ធនាគារខេត្ត ក្រុង ឱ្យបានសមស្របតាមតម្រូវការចាំបាច់ និងបទដ្ឋានអប្បបរមាអង្គការសហប្រជាជាតិ ស្តីពីការគ្រប់គ្រងអ្នកទោស
- គ្រប់គ្រង ត្រួតពិនិត្យ ទ្រព្យសម្បត្តិ ភស្តុភារ ហិរញ្ញវត្ថុ តាមការកំណត់របស់ក្រសួង
- សហប្រតិបត្តិការជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ និង ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ក្នុងវិស័យគ្រប់គ្រងមណ្ឌលអប់រំកែប្រែ និង ពន្ធនាគារ ជាក់ស្តែងតាមការកំណត់របស់ក្រសួង
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ធ្វើការងារបូកសរុប គ្រប់គ្រងឯកសារ របស់អគ្គនាយកដ្ឋានពន្ធនាគារ

**មាត្រា៥ ..**

មន្ត្រីអនុរក្សពន្ធនាគារ ត្រូវបានបំពាក់ឧបករណ៍ សម្ភារៈ បច្ចេកទេស ចាំបាច់តាមសំណូមពរការងារជាក់ស្តែង ដើម្បីធានាសុវត្ថិភាពពន្ធនាគារ

**មាត្រា៦ ..**

រចនាសម្ព័ន្ធអគ្គនាយកដ្ឋានពន្ធនាគារ រួមមាន :

- នាយកដ្ឋានប្រតិបត្តិ
- នាយកដ្ឋានអប់រំកែប្រែ
- នាយកដ្ឋានមធ្យោបាយ
- លេខាធិការដ្ឋាន
- មណ្ឌលអប់រំកែប្រែ

នៅថ្នាក់ខេត្ត ក្រុង មាន :

- ពន្ធនាគារ ខេត្ត ក្រុង ។

**មាត្រា៧ .-**

តួនាទីភារកិច្ច និង រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន នាយកដ្ឋាន មណ្ឌលអប់រំកែប្រែ ពន្ធនាគារខេត្ត ក្រុង និង ការិយាល័យចំណុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦*

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ដូចមាត្រា៩
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក
ចុះថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០០៦




G Dpt.doc